


# វិញ្ញាសាតែងសេចក្តី
# ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

បង្រៀនដោយ **វ៉ាន់ វី**
សាស្ត្រាចារ្យជំនួយនៃដេប៉ាតឺម៉ង់ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## វិញ្ញាសាទី២

**ប្រធាន៖** គេពោលថា « មានវិជ្ជាខ្វះសីលធម៌ នាំឱ្យមានគ្រោះថ្នាក់ » ។ ចូរបកស្រាយពំនោលខាងលើដោយលើកឧទាហរណ៍មកបញ្ជាក់ ។

# គម្រោងតែងសង្ខេប

## ១- សេចក្តីផ្តើម

**ក- លំនាំបញ្ហា៖** និយាយទូទៅអំពីទំនាក់ទំនងរវាងវិជ្ជានិងសីលធម៌ ។

**ខ- ចំណូលបញ្ហា៖** ហេតុដូច្នេះហើយ ទើបមានទស្សនៈលើកឡើងថា « មានវិជ្ជាខ្វះសីលធម៌ នាំឱ្យមានគ្រោះថ្នាក់ » ។

**គ- ចំណោទបញ្ហា៖** តើពំនោលខាងលើនេះមានអត្ថន័យយ៉ាងដូចម្តេច ?

## ២- តួសេចក្តី

**ក- ឃ្លាភ្ជាប់សេចក្តី៖** មុននឹងឈានដល់ការបកស្រាយមតិប្រធានឱ្យបានក្បោះក្បាយ យើងគួរគប្បីយល់ន័យរបស់ពាក្យ វិជ្ជា សីលធម៌ និងគ្រោះថ្នាក់ ជាមុនសិន ។

**ខ- ពន្យល់ពាក្យគន្លឹះ៖**

- **វិជ្ជា៖** ចំណេះដឹង សេចក្តីដឹងច្បាស់លើវិស័យផ្សេងៗ ។
- **សីលធម៌៖** ធម៌ដែលនាំឱ្យមានសណ្តាប់ធ្នាប់ ឱ្យចៀសវាងអំពើអាក្រក់ ឱ្យប្រព្រឹត្តតែអំពើល្អ មិនបៀតបៀនជីវិតមនុស្សនិងសត្វ ។
- **គ្រោះថ្នាក់៖** សេចក្តីអន្តរាយ ហេតុការណ៍អាក្រក់ ដែលកើតមានភ្លាមៗ ឬដោយចៃដន្យ ។

**គ- ពន្យល់ន័យប្រធាន៖** ដូច្នេះ មតិប្រធានខាងលើមានន័យថា បើមានតែចំណេះដឹងនានា ហើយខ្វះនូវធម៌ដែលនាំឱ្យមានសណ្តាប់ធ្នាប់ នោះនឹងបណ្តាលឱ្យប្រព្រឹត្តអំពើអាក្រក់ នាំមកនូវសេចក្តីអន្តរាយ ឬហេតុការណ៍អាក្រក់ផ្សេងៗជាមិនខាន ។

ឃ- បកស្រាយប្រធានៈ

**ឃ.១- គំនិតសំខាន់ទី១ៈ** បើមានតែចំណេះ ហើយខ្វះសីលធម៌ នោះនឹងនាំឱ្យអន្តរាយដល់ខ្លួនឯង ។

ឧទាហរណ៍ៈ

- សង្គមៈ បុគ្គលមានចំណេះ តែបែរជាប្រព្រឹត្តអសីលធម៌ នាំឱ្យអាប់កេរ្តិ៍ឈ្មោះ និងជួបតែគ្រោះភ័យ ។

- អក្សរសិល្ប៍ៈ ក្នុងរឿងកុលាបប៉ៃលិន លោកបាឡាត់មានចំណេះដឹង និងយសសក្តិ តែបានប្រព្រឹត្តខុសសីលធម៌ចំពោះនាងឃុននារី និងបានសមគំនិតជាមួយពួកចោរទុច្ចរិត ក៏ត្រូវអន្តរាយដល់ជីវិតនៅទីបញ្ចប់ ។

**ឃ.២- គំនិតសំខាន់ទី២ៈ** ការមានចំណេះដឹង តែយកទៅប្រើខុសផ្លូវ ក៏នាំឱ្យអ្នកដទៃ សង្គមជាតិ និងមនុស្សជាតិ ជួបនូវមហន្តរាយដែរ ។

ឧទាហរណ៍ៈ

- ប្រវត្តិសាស្ត្រៈ

មេដឹកនាំខ្មែរក្រហមបានរៀនសូត្រចេះដឹង ប៉ុន្តែបានប្រើចំណេះខុសផ្លូវ ដើរតាមមនោគមវិជ្ជាកុម្មុយនីស្តផ្តាច់ការ ក៏បណ្តាលឱ្យសង្គមខ្មែរធ្លាក់ចុះដល់ចំណុចសូន្យ និងនាំឱ្យមនុស្សរាប់លាននាក់ស្លាប់ ។

សមិទ្ធផលនៃវិជ្ជាមួយចំនួន បានបំផ្លាញពិភពលោក ជាពិសេសគឺគ្រាប់បែកបរមាណូត្រូវបានអ្នកវិទ្យាសាស្ត្របង្កើតឡើង ដោយបានបង្កវិនាសកម្មយ៉ាងធំធេងចំពោះមនុស្សជាតិ ។

- អក្សរសិល្ប៍ៈ រឿងគូលីកំណែន បានបង្ហាញថា តាង៉ែត យាយម៉ុក នាងហេង និងពលរដ្ឋជាច្រើននាក់ ត្រូវស្លាប់យ៉ាងអាណោចអាធ័ម ដោយសារតែការទម្លាក់គ្រាប់បែកនៅត្រង់ចេតិយវត្តឧណ្ណាលោម ។

**ឃ.៣- គំនិតសំខាន់ទី៣៖** ការប្រើវិជ្ជាដោយខ្វះសីលធម៌ ដើម្បីបម្រើមហិច្ឆតាផ្នែកសម្ភារៈរបស់មនុស្ស បានជះឥទ្ធិពលអាក្រក់ចំពោះធម្មជាតិ និងភពផែនដីរបស់យើង ។

ឧទាហរណ៍៖

- ការបង្កើតរោងចក្រនានា ជាពិសេសរោងចក្រនុយក្លេអ៊ែ បានបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ធម្មជាតិ ។

- យានយន្តប្រើប្រាស់ប្រេងឥន្ធនៈបានរួមចំណែកក្នុងការបំភាយឧស្ម័នពុលទៅក្នុងបរិយាកាសផែនដី នាំឱ្យអាកាសធាតុប្រែប្រួល ។

**ង- សរុប ៖** រួមសេចក្តីមក បើមានតែវិជ្ជា តែខ្វះសីលធម៌ នឹងបណ្តាលឱ្យគ្រោះថ្នាក់ដល់ខ្លួនឯង សង្គមនុស្ស និងបរិស្ថានធម្មជាតិ ។

## ៣- សេចក្តីបញ្ចប់

**ក- វាយតម្លៃប្រធាន៖** ប្រធាននេះមានអត្ថន័យជ្រាលជ្រៅសម្រាប់អប់រំមនុស្សទូទៅ គ្រប់ជាតិសាសន៍នៅលើពិភពលោក ឱ្យប្រកាន់ខ្ជាប់នូវតម្លៃសីលធម៌ បន្ថែមពីលើចំណេះវិជ្ជាដែលខ្លួនមាន ។

**ខ- យោបល់ផ្ទាល់ខ្លួន៖** យើងជាសិស្សានុសិស្ស ត្រូវខិតខំរៀនសូត្រឱ្យមានចំណេះវិជ្ជា និងចូលរួមចំណែកអភិវឌ្ឍសង្គមជាតិ ដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ដើម្បីឱ្យក្លាយខ្លួនជាពលរដ្ឋល្អ ។

# សេចក្ដីអធិប្បាយ

ចំណេះវិជ្ជាមានសារៈសំខាន់ពុំអាចកាត់ថ្លៃបានសម្រាប់មនុស្ស និងសង្គមជាតិនីមួយៗ។ មនុស្សណាក៏ដោយ សង្គមណាក៏ដោយ ក៏សុទ្ធតែត្រូវការចំណេះវិជ្ជា ដើម្បីអភិវឌ្ឍឱ្យចម្រើនលូតលាស់ទៅមុខ។ វិជ្ជានោះ បើគេយកទៅប្រើបានត្រឹមត្រូវ បុគ្គលនោះ សង្គមនោះក៏ច្បាស់ជានឹងរីកចម្រើន ស្គាល់នូវភាពរុងរឿងត្រចះត្រចង់។ ប៉ុន្តែ បើគេយកចំណេះដឹងទៅប្រើក្នុងផ្លូវខុស ដោយខ្វះសីលធម៌ នោះប្រាកដជាជួបនឹងសេចក្ដីអន្តរាយជាក់ជាពុំខាន។ ហេតុដូច្នេះហើយ ទើបមានទស្សនៈលើកឡើងថា «មានវិជ្ជាខ្វះសីលធម៌ នាំឱ្យមានគ្រោះថ្នាក់»។

តើពំនោលខាងលើនេះមានអត្ថន័យយ៉ាងដូចម្ដេច ?

មុននឹងឈានដល់ការបកស្រាយប្រធានឱ្យបានក្បោះក្បាយ យើងគួរយល់ន័យរបស់ពាក្យ វិជ្ជា សីលធម៌ និងគ្រោះថ្នាក់ ជាមុនសិន។ វិជ្ជា សំដៅដល់ ចំណេះដឹង ការចេះដឹង សេចក្ដីដឹងច្បាស់លើវិស័យផ្សេងៗ។ ចំណែកសីលធម៌ មានន័យថា ធម៌ដែលនាំឱ្យមានសណ្ដាប់ធ្នាប់ ឱ្យចៀសវាងអំពើអាក្រក់ ឱ្យប្រព្រឹត្តតែអំពើល្អ មិនបៀតបៀនជីវិតមនុស្ស សត្វ ជាដើម។ ឯគ្រោះថ្នាក់ បានសេចក្ដីថា សេចក្ដីអន្តរាយ ហេតុការណ៍អាក្រក់ ដែលកើតមានភ្លាមៗ ឬដោយចៃដន្យ។ ដូច្នេះ មតិប្រធានខាងលើមានន័យថា បើមានតែចំណេះដឹងផងនានា តែខ្វះនូវធម៌ដែលជួយឱ្យមានសណ្ដាប់ធ្នាប់ នោះនឹងបណ្ដាលឱ្យប្រព្រឹត្តអំពើអាក្រក់ នាំមកនូវសេចក្ដីអន្តរាយ ឬហេតុការណ៍អាក្រក់ផ្សេងៗជាពុំខាន។

ពិតណាស់ ចំណេះវិជ្ជានាំឱ្យមនុស្សនិងសង្គមមនុស្សចម្រើនលូតលាស់ទៅមុខ ប្រសិនបើគេយកវាទៅប្រើប្រាស់ក្នុងផ្លូវត្រឹមត្រូវ។ ប៉ុន្តែ បើមានតែចំណេះហើយខ្វះសីលធម៌វិញ នោះនឹងនាំឱ្យអន្តរាយដល់ខ្លួនឯង។ នេះបានន័យថា បើមានតែចំណេះដឹង តែបែរជាខ្វះសីលធម៌ ប្រាកដជាយកចំណេះនោះទៅអនុវត្តខុសទិសដៅ ឬ

ចាកពីប្រយោជន៍រួម ពោលគឺបំពេញតែមហិច្ឆតាផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ នៅក្នុងសង្គមជាក់ស្តែង យើងតែងសង្កេតឃើញថា បើបុគ្គលណាមានចំណេះដឹង តែប្រព្រឹត្តចាកសីលធម៌ ខ្វះវិចារណញ្ញាណ បុគ្គលនោះច្រើនតែអាប់យស អាប់កេរ្តិ៍ឈ្មោះ និងឈានដល់សេចក្តីវិនាសទៀតផង។ នេះបានសេចក្តីថា មានចំណេះវិជ្ជា បើគ្មានសីលធម៌ទេ ទោះជាចេះយ៉ាងណាក៏ដោយ ក៏គ្មានតម្លៃឱ្យគេគោរពដែរ។ បើក្រឡេកមកមើលអក្សរសិល្ប៍ខ្មែរវិញ យើងក៏សង្កេតឃើញថាដូច្នេះដែរ។ ជាតួយ៉ាង នៅក្នុងប្រលោមលោករឿងកុលាបប៉ៃលិន របស់លោក ញ៉ុក ថែម យើងឃើញថា តួអង្គបាឡាត់ជាអ្នកមានចំណេះវិជ្ជា រហូតមានតំណែងជាបាឡាត់ស្រុកសង្កែ តែបែរជាមានបូកពារក្រអឺត និងហ៊ានប្រព្រឹត្តប្រាសចាកសីលធម៌ ដោយរកវិធីបំពាននាងយុវនារីជាច្រើនលើក ហើយថែមទាំងចូលដៃជាមួយមេចោរទុច្ចរិត ឈ្មោះផាន់ ទៅប្លន់ផ្ទះរបស់លោកហ្លួងរតនសម្បត្តិទៀតផង។ ចុងក្រោយ លោកបាឡាត់ក៏ត្រូវអន្តរាយរហូតដល់អស់ជីវិតរបស់ខ្លួន ក៏ព្រោះតែអំពើខ្វះសីលធម៌ ខ្វះវិចារណញ្ញាណនេះឯង។

ការមានចំណេះដឹង តែយកទៅប្រើខុសផ្លូវនេះ ពុំមែនឱ្យទុក្ខទោសសម្រាប់តែបុគ្គលប៉ុណ្ណោះទេ វានាំឱ្យអ្នកដទៃ សង្គមជាតិ និងមនុស្សជាតិ ជួបនូវមហន្តរាយដែរ។ មនុស្សយើងរស់នៅជាសង្គម ហេតុនេះអំពើណាមួយដែលធ្វើទៅ នឹងជះឥទ្ធិពលដល់សង្គមជាមិនខាន។ បើសមាជិកនៃសង្គមនោះ យកចំណេះដឹងរបស់ខ្លួនទៅប្រើដោយខុសសីលធម៌ សង្គមក៏នឹងត្រូវរងផលប៉ះពាល់ទៅតាមនោះដែរ។ ជាតួយ៉ាង មេដឹកនាំរបបខ្មែរក្រហម ភាគច្រើនជាអ្នកមានចំណេះដឹង បានទៅសិក្សារហូតដល់បរទេសខ្លះផង ប៉ុន្តែបែរជាប្រើចំណេះរបស់ខ្លួនដើរតាមគន្លងមនោគមវិជ្ជាកុម្មុយនីស្តផ្តាច់ការមហាលោតផ្លោះ ដឹកនាំប្រទេសឱ្យវិនាសហិនហោច ធ្លាក់ចុះដល់ចំណុចសូន្យ ហើយថែមទាំងបណ្តាលឱ្យប្រជាជនខ្លួនឯងស្លាប់អស់ជាច្រើនលាននាក់ទៀតផង។ ក្រៅពីនេះ យើងសង្កេតឃើញថា សមិទ្ធផលនៃវិជ្ជាមួយចំនួន ដែលបានបង្កើតឡើងសម្រាប់

បម្រើមហិច្ឆតាលោភលន់ បានក្លាយជាគ្រឿងសម្រាប់សម្លាប់សត្វ មនុស្ស និងបំផ្លាញពិភពលោក មានដូចជា ថ្នាំពុល កាំភ្លើងតូចធំ រថក្រោះ នាវាចម្បាំង យន្តហោះចម្បាំង អាវុធគីមី គ្រាប់មីន គ្រាប់បែកបរមាណូ ជាដើម។ គ្រឿងប្រហារទាំងអស់នេះ សុទ្ធតែកើតឡើងពីចំណេះវិជ្ជានេះឯង។ ជាក់ស្តែង ដូចកាលពីក្នុងសង្គ្រាមលោកលើកទីពីរ ការទម្លាក់គ្រាប់បែកបរមាណូនៅហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី នាប្រទេសជប៉ុន បានបង្កវិនាសកម្មយ៉ាងធំធេង សម្លាប់ជីវិតមនុស្ស បំផ្លាញប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគ្រប់បែបយ៉ាង។ ដោយឡែក អក្សរសិល្ប៍ទំនើបខ្មែររឿងគូលីកំណែន របស់អ្នកនិពន្ធ អ៊ឹម ថុក ដែលបោះពុម្ពនៅឆ្នាំ១៩៥៦ បានបង្ហាញថា តាង៉ែត យាយម៉ុក នាងហេង និងពលរដ្ឋជាច្រើននាក់ ត្រូវស្លាប់យ៉ាងអាណោចអាធ័មដោយការទម្លាក់គ្រាប់បែកលើមូលដ្ឋានទ័ពជប៉ុននៅត្រង់ចេតិយវត្តឧណ្ណាលោម នាទីក្រុងភ្នំពេញ។

មិនតែប៉ុណ្ណោះ ទុក្ខទោសនៃការប្រើវិជ្ជាដោយខ្វះសីលធម៌ ដើម្បីបម្រើមហិច្ឆតាផ្នែកសម្ភារះរបស់មនុស្ស ពុំមែនប៉ះពាល់ត្រឹមតែកម្រិតបុគ្គល និងសង្គមមនុស្សប៉ុណ្ណោះទេ វាក៏បង្កសេចក្តីអន្តរាយដល់ធម្មជាតិ និងភពផែនដី ដែលយើងរស់នៅទៀតផង។ ជាក់ស្តែង ការបង្កើតរោងចក្រផលិតសម្ភារះបច្ចេកទេសនានា និងជាពិសេសនោះគឺរោងចក្រថាមពលនុយក្លេអ៊ែ បានជួយឱ្យសង្គមមនុស្សរីកចម្រើនលឿនក្នុងផ្នែកសម្ភារះក៏ពិតមែនហើយ តែវាក៏បង្កផលអាក្រក់ដល់បរិស្ថាននៃពិភពលោកនេះដែរ។ ទន្ទឹមគ្នានេះ យានយន្តប្រើប្រេងឥន្ធនៈនានាក៏បានបង្កផលប៉ះពាល់យ៉ាងចម្បងដល់បរិស្ថាន។ គេរកឃើញថា គិតត្រឹមឆ្នាំ២០១៣ វិស័យដឹកជញ្ជូនបានចូលរួមចំណែកលើសពាក់កណ្តាលនៃការបំភាយឧស្ម័នពុលទាំងអស់ ជាពិសេសគឺឧស្ម័នកាបូនិក ហើយស្មើរតែមួយភាគបួននៃឧស្ម័នទាំងអស់នោះ បានបញ្ចេញទៅក្នុងបរិយាកាស។ ឧស្ម័នពុលទាំងនោះ គឺជាឧស្ម័នផ្ទះកញ្ចក់ ដែលបណ្តាលឱ្យផែនដីខូចស្រទាប់អូសូន នាំឱ្យឡើងកម្តៅផែនដី រហូតដល់មានបម្រែបម្រួលអាកាសធាតុខុសពី

ប្រក្រតីទៀត។ ថ្មីៗនេះ អ្នកវិទ្យាសាស្ត្ររកឃើញថា កំណើនកម្ដៅផែនដីបានកើតឡើងរហូតដល់ជាង ១ អង្សាសេក្នុងអំឡុងពេល ១០ ឆ្នាំចុងក្រោយនេះ។

រួមសេចក្តីមក បើមានតែចំណេះវិជ្ជា តែខ្វះសីលធម៌ នឹងបណ្តាលឱ្យគ្រោះមានថ្នាក់ដល់ខ្លួនឯង សង្គមមនុស្ស និងបរិស្ថានធម្មជាតិ។ វិជ្ជានិងសីលធម៌គឺជាចរន្តពីរ និងជាគុណសម្បត្តិពីរ ដែលមិនអាចកាត់ផ្តាច់ពីគ្នាបានទេ ពោលគឺត្រូវដើរទន្ទឹមគ្នាទើបប្រសើរ។

ឆ្លងតាមការបកស្រាយខាងលើ យើងឃើញថា ប្រធាននេះមានអត្ថន័យដ៏ល្អប្រសើរសម្រាប់អប់រំមនុស្សទូទៅ គ្រប់ជាតិសាសន៍នៅលើពិភពលោក ឱ្យប្រកាន់ខ្ជាប់នូវតម្លៃសីលធម៌បន្ថែមពីលើចំណេះវិជ្ជា ឱ្យស្គាល់ពីតម្លៃជីវិត និងលះបង់នូវមហិច្ឆតាល្មោភសង្គ្រាម បញ្ឈប់ការផលិតអាវុធប្រល័យលោក ព្រមទាំងកាត់បន្ថយការផលិតសម្ភារៈដែលបង្កផលប៉ះពាល់មនុស្សជាតិតាមតែអាចធ្វើបាន។ យើងជាសិស្សានុសិស្ស ត្រូវខិតខំរៀនសូត្រឱ្យមានចំណេះវិជ្ជា ព្រមទាំងប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ដើម្បីឱ្យក្លាយខ្លួនជាពលរដ្ឋល្អ ដែលអាចរួមរស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមរមនា ហើយកសាងសង្គមនិងពិភពលោកឱ្យក្លាយជាទីដ៏ប្រពៃ។

# ឯកសារពិគ្រោះ


កាន់ ចាន់ដារ៉ា និង វ៉ាន់ វី *តែងសេចក្តី៖ ប្រធានពន្យល់* ភ្នំពេញ ឆ្នាំ២០១២។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្តី*** *(សម្រាប់មធ្យមសិក្សាទុតិយភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្តី*** *(សម្រាប់មធ្យមសិក្សាបឋមភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨។

សែម សូរ, ថោង ផែល និងអ្នកដទៃទៀត ***វិញ្ញាសាតែងសេចក្តីគំរូ*** បណ្ណាគារមាយើង ឆ្នាំ១៩៧១។